ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ: ..613..... PEAC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការចូលរួមដេញថ្លៃ ឈ្នួលពលកម្មសាងសង់បណ្តាញអគ្គិសនីក្នុងផែនការឆ្នាំ 2017 ជូនអគ្គិសនីខេត្តចំនួន 07 (តាកែវ-កំពត-ព្រះសីហនុ-សៀមរាប-បន្ទាយមានជ័យ-បាត់ដំបង-កំពង់ស្ពឺ) (កញ្ចប់ 21 ឡូត៍ទី 3)

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការសាងសង់បណ្តាញអគ្គិសនីក្នុងផែនការឆ្នាំ 2017 ជូនអគ្គិសនីខេត្ត ចំនួន 07 (តាកែវ-កំពត-ព្រះសីហនុ-សៀមរាប-បន្ទាយមានជ័យ-បាត់ដំបង-កំពង់ស្ពឺ) (កញ្ចប់ 21 ឡូត៍ទី 3) ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី..29..... ខែ មិថុនា...ឆ្នាំ ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី 29.... ខែ សីហា... ឆ្នាំ ២០១៧ វេលាម៉ោង ១៤:០០ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង 15:30..ថ្ងៃទី..29 ខែ សីហា...ឆ្នាំ ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៧
ប្រធានគណៈកម្មាធិការលទ្ធកម្ម

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ធីង_អ៊ីង

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ